# សហគមន៍ខ្មែរកម្ពុជាក្រោម

KHMER KAMPUCHEA KROM COMMUNITY

LA COMMUNAUTÉ DU KHMER KAMPUCHEA KROM


លេខ........................................ ស.ខ.ក.ក.

# សេចក្តីប្រកាសពត៌មាន

កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៨ ឯកឧត្តម MARCO PANNELLA អនុប្រធានសភាសហគមន៍អឺរ៉ុប ប្រធាន TRANSNATIONAL RADICAL PARTY(TRT)និងឯកឧត្តម MARCO PERDUCA សមាជិកសភាសហគមន៍អឺរ៉ុប អគ្គលេខាធិការUnrepresentative Peoples Organization(UNPO) បានអញ្ជើញមកបំពេញទស្សនកិច្ចសហគមន៍ខ្មែរកម្ពុជាក្រោមនៅព្រះរាជាណាចក្រកម្ពុជា។ អញ្ជើញទទួលស្វាគមន៍គណៈប្រតិភូមានឯកឧត្តមថាច់-សេដ្ឋា អតីតសមាជិកព្រឹទ្ធសភា ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម។ ឯកឧត្តមយន្ត ថារូ សមាជិករដ្ឋសភាប្រ-ធានមជ្ឈមណ្ឌលវប្បធម៌ខ្មែរកម្ពុជាក្រោម។ល។ និងមានការនិមន្តនិងអញ្ជើញចូលរួម ពីព្រះសង្ឃ ថ្នាក់ ដឹកនាំ និងសមាជិក សមាជិកា នៃអង្គការ-សមាគមខ្មែរកម្ពុជាក្រោមផ្សេងទៀត យ៉ាងច្រើនកុះករ។

កិច្ចប្រជុំបានធ្វើឡើងនៅវត្តសាមគ្គីរង្សី រាជធានីភ្នំពេញ។ បន្ទាប់ពីកិច្ចស្វាគមន៍ ឯកឧត្តមថាច់ សេដ្ឋា បានលើកសំណើចំនួន១២ចំណុចជូនគណៈប្រតិភូអន្តរាគមន៍ទៅរដ្ឋាភិបាលវៀតណាម ដើម្បីជួយដល់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោម ក្នុងឱកាសដែលគណៈប្រតិភូនេះទៅបំពេញទស្សនកិច្ចនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៨ខាងស្អែកនេះ។

ឆ្លើយតប និងសំណើឯកឧត្តមថាច់ សេដ្ឋា ឯកឧត្តមMARCO PANNELLA បានថ្លែងថា ឯកឧត្តមគាំទ្រយ៉ាងពេញទំហឹង ហើយលោកនៅជាមួយសហគមន៍ខ្មែរកម្ពុជាក្រោមជានិច្ច ដើម្បីរួមកម្លាំងគ្នាប្រយុទ្ធតស៊ូក្នុងបុព្វហេតុសិទ្ធិសេរីភាពរបស់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោម។ ឯកឧត្តមបានកោតសរសើរដល់ការតស៊ូរបស់ព្រះសង្ឃ និងប្រជារាស្ត្រខ្មែរកម្ពុជាក្រោម ហើយថា តាមរយៈនៃការតស៊ូនេះ ឥឡូវនេះ សហគមន៍អន្តរជាតិបានដឹងអំពីទុក្ខវេទនារបស់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមហើយ សូមឲ្យយើងទាំងអស់គ្នារួមសាមគ្គីគ្នាតស៊ូតទៅមុខទៀតរហូតទទួលបានសិទ្ធិសេរីភាព។

បន្ទាប់មកឯកឧត្តម MARCO PERDUCA បានថ្លែងជំរាបជូនអង្គប្រជុំថា UNPO&TRT និងរៀបចំសិក្ខាសាលាមួយសំរាប់ពលរដ្ឋខ្មែរកម្ពុជាក្រោម និងមានរៀបចំធ្វើមហាបាតុកម្មដ៏ធំមួយ ដើម្បីទាមទារសិទ្ធិសេរីភាពជូនប្រជារាស្ត្រខ្មែរកម្ពុជាក្រោម នៅប្រទេសកម្ពុជានាឆ្នាំ២០០៩ខាងមុខនេះ។ រីឯកាលបរិច្ឆេទនិងពិភាក្សាជាមួយសហគមន៍ខ្មែរកម្ពុជាក្រោមនៅពេលក្រោយ។

កិច្ចប្រជុំចាប់ផ្តើមពីម៉ោង២រសៀលរហូតដល់ម៉ោង៥ល្ងាច បានបញ្ចប់ក្រោមបរិយាកាសយ៉ាងសប្បាយរីករាយ ប្រកបដោយក្តីសង្ឃឹមយ៉ាងក្រៃលែង។

ភ្នំពេញថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨

លេខាធិការដ្ឋានសហគមន៍ខ្មែរកម្ពុជាក្រោម


ភូមិគ្រឹះលេខ៩៦ , ផ្លូវ៣៧១ , ភូមិត្រពាំងឈូក , សង្កាត់ទឹកថ្លា , ខណ្ឌឫស្សីកែវ , រាជធានីភ្នំពេញ

ទូរស័ព្ទ-ទូរសារលេខ : (៨៥៥) ២៣ ៩៩៥ ៥៨១, ១២ ៨៥១ ៩៩១ / ៩០ ៨៨ ៨២.

អ៊ីមែល: kkcommunity@camintel.com or k.k.k.c@camitel.com; website: http://khmerkromngo.org